# ឯកឧត្តម ចម ប្រសិទ្ធ ជួបប្រតិភូសមាគមសហគ្រិនស្ត្រីកម្ពុជា



នៅរសៀលថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០១៥ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអនុញ្ញាតឱ្យប្រតិភូសមាគមសហគ្រិនស្ត្រីកម្ពុជា ដែលមានលោកស្រី **សេង តក្កនារី** ជាប្រធាន ដើម្បីចូលជួបសំដែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោកស្រី **សេង តក្កនារី** ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា គឺ **ទី១:**ធ្វើសេចក្តីរាយការណ៍សង្ខេបពីប្រវត្តិ និងសកម្មភាពការងាររបស់សមាគម និង **ទី២:** បង្ហាញពីមោទនភាពដែលក្រុមហ៊ុនចំនួន០៦ ដែលភាគច្រើនបំផុតស្ថិតក្នុងសមាគមរបស់លោកស្រី ត្រូវបានទទួលពានរង្វាន់ជាសហគ្រិនស្ត្រីឆ្នើម ដែល

ជាការជ្រើសរើសសហគ្រិនស្ត្រីនៅប្រទេសកម្ពុជា សម្រាប់ចូលរួមប្រកួតប្រជែងជាមួយសហគ្រិនស្ត្រីនៃបណ្តាប្រទេសអាស៊ានចំនួន ៩ ប្រទេសទៀត ។ ទាក់ទងនិងប្រវត្តិសមាគម លោកស្រី ប្រធាន បានជម្រាបជូនថាៈ សមាគមបានកកើតឡើងនៅឆ្នាំ២០១១ ដោយមានការជួយជ្រោមជ្រែងពីមន្ត្រីធនាគារពិភពលោក និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមានការជួយមូលនិធីពីដៃគូបរទេស ក្រុមហ៊ុន និងស្ថានទូតមួយចំនួនដូចជាស្ថានទូត ស៊ុយ អែត និង ហ្វាំងឡង់ ជាដើម ។ បច្ចុប្បន្នសមាគមមានសមាជិក ចំនួន ២០៣ ក្រុមហ៊ុន និងចំនួន២២វិស័យ ។ ក្នុងនោះ សមាជិកសមាគម មានជាតិសាសន៏ចម្រុះដោយផ្អែកតាមគោលការណរបស៏សមាគមដែលមិនប្រកាន់ពូជសាសន៏ ពណ៌សម្បុរ គឺឱ្យតែម្ចាស់សហគ្រិនជាស្ត្រី និងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមានរបបប្រជុំក្រុមប្រឹក្សាជារៀងរាល់ខែ មានវគ្គបណ្តុះបណ្តាល បង្កើតឱ្យមានមជ្ឈមណ្ឌលឯកសារ និងការចែករំលែក ព័តិមានដល់សមាជិករបស់ខ្លួន ។ ចំពោះក្រុមហ៊ុនទាំង០៦ ដែលទទួលពានរង្វាន់សហគ្រិនស្ត្រីឆ្នើម មានវិស័យផ្សេងៗគ្នា មានវិស័យ សូត្រ-អចនទ្រព្យ-ឧស្សាហកម្មទេសចរណ៏-សិប្បកម្មកែច្នៃម្ហូបអាហារ-ពេទ្យធ្មេញ-និងក្រុមហ៊ុនផលិតនំស្រួយ ។ សមាគមនឹងប្រារព្ធពិធី អបអរសាទរនូវអណត្តិជោគជ័យ០៣ឆ្នាំរបស់ខ្លួន នៅថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០១៥ ខាងមុខនេះ ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសំដែងការស្វាគមន៏ និងវាយតម្លៃខ្ពស់ ចំពោះសកម្មភាពការងាររបស់សមាគម និងអបអរសាទរចំពោះក្រុមហ៊ុនទាំង០៦ ដែលមានម្ចាស់ជាសហគ្រិនស្ត្រី ក្នុងប្រទេសកម្ពុជា ទទួលបាននូវពានរង្វាន់ជាសហគ្រិនស្ត្រីឆ្នើម សម្រាប់ចូលរួមប្រកួតប្រជែងក្នុងតំបន់អាស៊ាន ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានកោតសរសើរផងដែរ ដល់កិច្ចខិតខំប្រឹងប្រែងរបស់សហគ្រិនជាស្ត្រី ក្នុងការអភិវឌ្ឍន៏ក្រុមហ៊ុន និងសហគ្រាសរបស់ខ្លួន ដោយទទួលបានពានរង្វាន់ និងវិញ្ញាបនបត្របញ្ជាក់គុណភាពផលិតផល និងសេវាទាំងថ្នាក់ជាតិ និងអន្តរជាតិជាច្រើន ។ ក្នុងនោះក៏មានទទួលបានវិញ្ញាបនបត្របញ្ជាក់នូវការអនុវត្តគោលការណ៏ ស ៥ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្មផងដែរ។

ដើម្បីឱ្យសមាគមមានដំណើរកាន់តែរីកចម្រើនទៅមុខ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើឱ្យសមាគមយកចិត្តទុដាក់ជាសំខាន់ទៅលើការបណ្តុះបណ្តាល ការចែករំលែកបទពិសោធន៏ ចំណេះដឹង និងព័តិមាន ហើយក្រសួងឧស្សាហកម្ម

និងសិប្បកម្ម គាំទ្រជានិច្ចរាល់សកម្មភាពរបស់សមាគម ហើយចាត់ទុកជាដៃគូរបស់ក្រសួង ពីព្រោះសមាគមនេះបណ្តុំដោយសហគ្រាសធុនតូច និងមធ្យម ដែលក្រសួងកំពុងរៀបចំគោលនយោបាយលើកទឹកចិត្ត ហើយរាជរដ្ឋាភិបាលកម្ពុជាក៏កំពុងយកចិត្តទុដាក់ដល់ស្ថានភាពស្ត្រីជាអ្នកដឹកនាំ និងធ្វើសេចក្តីសម្រេចចិត្តផងដែរ ។



